# ព្រឹត្តិបត្រប្រចាំត្រីមាសទី២

ទឹកស្អាតសម្រាប់មនុស្សគ្រប់រូប

ខែមេសា ដល់ ខែមិថុនា ឆ្នាំ២០២៤

## ១. បច្ចុប្បន្នភាពសមាគម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជនមិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

សមាគមបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយក្រុមអ្នកផ្គត់ផ្គង់ទឹកស្អាតឯកជនមួយក្រុមមានគ្នាប្រមាណជា ២០នាក់ ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង អេម អេស អេម អ៊ី កម្ពុជា (MSME) ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងបានចុះបញ្ជីសមាគមជាផ្លូវការនៅក្រសួងមហាផ្ទៃ តាមសេចក្តីជូនដំណឹងលេខ: ១០៧៧ សជណ របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២។ ក្រសួងមហាផ្ទៃចេញសេចក្តីប្រកាសលេខ: ២៩០១ ប្រក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ សម្រេចចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គល នៅក្រសួងមហាផ្ទៃ ដោយមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលស្ថិតនៅអគារ F ជាន់ទី២ បន្ទប់លេខ ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគមបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

គិតត្រឹមបំណាច់ត្រីមាសទី២ ឆ្នាំ២០២៤ សមាគមមានសមាជិកសរុបចំនួន ៣២៩ស្ថានីយ / ក្រុមហ៊ុន ដែលបាននឹងកំពុងប្រតិបត្តិការនៅក្នុង ២៣រាជធានី/ខេត្ត/ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះមានសមាជិកអាជីពចំនួន ២៨៥ស្ថានីយ និងសមាជិកគាំទ្រចំនួន ៤៤ក្រុមហ៊ុន។

## ២. ក្រុមប្រឹក្សាភិបាល

### ២.១ ការចូលជួបសម្តែងការគួរសម

ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាលសមាគម អាណត្តិទី២ ទាំង ៩នាក់ (ស្រី ២នាក់) បានចូលជួបសម្តែងការគួរសម និងសុំអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម ហែម វណ្ណឌី** រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧវបន) សម្រាប់ជាចក្ខុវិស័យក្នុងការដឹកនាំសមាគមក្នុងអាណត្តិថ្មី ឱ្យទទួលបានជោគជ័យទៅតាមផែនការយុទ្ធសាស្ត្រ បេសកកម្ម និងទស្សនវិស័យរបស់សមាគម ពោលគឺផ្តល់ឱ្យប្រជាពលរដ្ឋកម្ពុជាទទួលបានទឹកស្អាតប្រកបដោយគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ។



*រូបភាពទី១៖ ការចូលជួបសម្ដែងការគួរសមរបស់ក្រុមប្រឹក្សាភិបាលនៅក្រសួង ឧវបន*

ក្នុងជំនួបសម្ដែងការគួរសមនេះ ក្រុមប្រឹក្សាភិបាលសមាគមបានស្នើសុំ **ឯកឧត្ដមរដ្ឋមន្ត្រី** ដូចខាងក្រោម៖

១. ប្រតិបត្តិករផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាតឯកជន ដែលទទួលបានប្រកាសអនុញ្ញាត (ឬអាជ្ញាបណ្ណ)ពីក្រសួង ឧវបន ទាំងអស់ចូលជាសមាជិករបស់សមាគម។

២. ប្រតិបត្តិករផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាតឯកជន ទទួលបានការលើកលែងពន្ធលើ ប្រាក់ចំណូល (ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ) ពន្ធអាករបន្ថែម(VAT ១០%)ទៅលើការភ្ជាប់សេវាអតិថិជន ប្រាក់រំដោះពន្ធលើប្រាក់ចំណូល (អត្រា ១%លើផលរបរប្រចាំខែ) ពន្ធអប្បរមា(អត្រា១% លើផលរបរប្រចាំឆ្នាំ)។

៣. មានយន្ដការច្បាស់លាស់ក្នុងការដោះស្រាយការខូចខាតបំពង់ទឹកស្អាតដោយការឈូសឆាយផ្លូវថ្នល់ពោលគឺសុំឱ្យមានសំណងសមរម្យលើការខូចខាតបំពង់ទឹកស្អាត។

៤. ជួយរកប្រភពហិរញ្ញប្បទានសម្រាប់ប្រតិបត្តិករផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាតឯកជន។

## ២.២ កិច្ចប្រជុំប្រចាំត្រីមាស

នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ សមាគមបានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រីមាសទី១ ឆ្នាំ២០២៤ ដែលមានការចូលរួមពី ក្រុមប្រឹក្សាភិបាលចំនួន ៨នាក់(ស្រីចំនួន ២នាក់) និង បុគ្គលិកសមាគមចំនួន ៤នាក់(ស្រីចំនួន ២នាក់) សរុបមានចំនួន ១២នាក់ (ស្រីចំនួន ៤នាក់)។ ក្រុមប្រឹក្សាភិបាលដែលបានអញ្ជើញមកការិយាល័យសមាគមមានចំនួន ៥នាក់ (ស្រីចំនួន ១នាក់) និងតាមប្រព័ន្ធអនឡាញ (ZOOM Call) មានចំនួន ៣នាក់ (ស្រីចំនួន១នាក់)។ របៀបវារៈនៃអង្គប្រជុំ ផ្ដោតទៅលើ ១). លទ្ធផលការងារត្រីមាសទី១ និងផែនការត្រីមាសទី២ របស់សមាគម ២). ពិនិត្យឡើងវិញនូវគោលនយោបាយសមាជិកភាព ៣). បទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សាភិបាល។

នៅក្នុងត្រីមាសទី១ ឆ្នាំ២០២៤ ការងារស្នូលសមាគមសម្រេចបានលទ្ធផលដូចខាងក្រោម៖

ទទួលបានសមាជិកថ្មីចំនួន ៧ ក្នុងនោះមានសមាជិកអាជីពចំនួន៥ និងសមាជិកគាំទ្រ ចំនួន ២។ បានរៀបចំសន្និបាតសមាគមលើកទី១២ ព្រមទាំងបានបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាភិបាលអាណត្តិទី២ (២០២៤-២០២៧) បានចំនួន ៩នាក់ (ស្រីចំនួន ២នាក់) ។ ជាមួយគ្នានេះដែរសមាគមក៏បានរៀបចំកិច្ចប្រជុំវិសាមញ្ញសម្រាប់ក្រុមប្រឹក្សាភិបាលតាមអនឡាញ ១លើក និងប្រជុំផ្ទាល់ ១លើក ជាងនេះ

ទៅទៀតសមាគមបានរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងការងារប្រចាំឆ្នាំរវាងក្រុមប្រឹក្សាភិបាល និងបុគ្គលិកនៅខេត្តកំពត។

យើងបានរៀបចំដំណើរកម្សាន្តប្រចាំឆ្នាំសម្រាប់សមាជិកទៅកាន់ក្រៅប្រទេស ចំនួន ១លើក (កោះត្រល់ ប្រទេសវៀតណាម)។ ក្នុងនោះដែរសមាគមបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់ចំនួន ១លើក នៅក្នុងខេត្តសៀមរាប ព្រមទាំងបានគាំទ្រ និងសម្របសម្រួលកិច្ចប្រជុំដោះស្រាយបញ្ហាសមាជិកបានចំនួន ១ករណី (ស្ថានីយផ្គត់ទឹកស្អាតព្រែករំដេង) និងបានផ្តល់ជំនួយបច្ចេកទេសក្នុងការធ្វើជ្យាតេស្តទឹកផៅដល់ប្រតិបត្តិករចំនួន១ស្ថានីយ និងប្រឹក្សាយោបល់អំពីបច្ចេកទេសក្នុងផលិតទឹកស្អាតដល់ប្រតិបត្តិករចំនួន៧ស្ថានីយ។

ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួង ឧវបន។ សមាគមបានសម្របសម្រួលរៀបចំសិក្ខាសាលាស្តីពីទឹកស្អាត និងប្រព័ន្ធ អនាម័យកម្ពុជាជប៉ុន ២០២៤ លើកទី១៦ ជាមួយសមាគមអាជីវកម្មទឹកក្រៅប្រទេស ក្រុងគីតាយ្យូស៊ុ (KOWBA) ក្រសួងឧវបន អង្គភាពទឹកស្អាត និងប្រព័ន្ធអនាម័យទីក្រុងគីតាយ្យូស៊ី និងបានរៀបចំវគ្គបណ្តុះបណ្តាលដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជនបានចំនួន ៣វគ្គ។

ការងារគម្រោងក្នុងត្រីមាសទី១ ឆ្នាំ២០២៤ សម្រេចលទ្ធផលដូចខាងក្រោម៖១. **គម្រោង«ការកែលម្អលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅកម្ពុជា ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត» គាំទ្រដោយអង្គការ Water.org**

- **ការពង្រឹងសមត្ថភាពប្រតិបត្តិករលើផ្នែកបច្ចេកទេស៖** ក្រុមការងារបានតាមដានការតេស្តគុណភាពទឹកស្អាតរបស់សមាជិកក្នុងគម្រោង ផ្តល់យោបល់ជូនស្ថានីយទឹកស្អាតតេដោមានជ័យលើរបាយការណ៍ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ និងសម្របសម្រួលទិញឧបករណ៍ជ្យាតេស្តជូនប្រតិបត្តិករថ្មីដោយមានការចូលរួមបដិភាគពីគម្រោង និងប្រតិបត្តិករផ្ទាល់។
- **ការពង្រឹងសមត្ថភាពប្រតិបត្តិករលើប្រព័ន្ធគណនេយ្យ៖** សម្រមសម្រួលការជួបប្រជុំរវាងប្រតិបត្តិករទាំង៥ស្ថានីយ ជាមួយនឹងក្រុមហ៊ុន EAST WING AUTIDTING & CONSULTING CO., LTD ដើម្បីពិភាក្សាអំពីបញ្ហាប្រឈមការបើកសមតុល្យដើមគ្រា។
- **ការសម្របសម្រួលកម្ចីរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងស្ថាប័នហិរញ្ញវត្ថុ៖** ១) សម្របសម្រួលអញ្ជើញប្រតិបត្តិករមួយស្ថានីយ ដើម្បីស្វែងយល់អំពី Water Equity និងស្វែងរកឱកាសទទួលបានមូលនិធិពី Water Equity ២) រៀបចំជាសេចក្តីប្រកាសស្វែងរកក្រុមហ៊ុនទីប្រឹក្សា ដើម្បីរៀបចំផែនការមេសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត និងប្រកាសជ្រើសរើសប្រតិបត្តិករចំនួន៦ស្ថានីយ ដើម្បីចូលរួមក្នុងគម្រោងសិក្សាផែនការមេនេះផងដែរ ៣) សម្របសម្រួលកម្ចីជូនប្រតិបត្តិករចំនួនមួយស្ថានីយជាមួយធនាគារ ជាលទ្ធផលប្រតិបត្តិករទឹកស្អាតនេះបានទទួលការអនុម័តកម្ចីពីធនាគារសហគ្រាសធុនតូច និងមធ្យម (SME) ដែលមានទំហំទឹកប្រាក់ចំនួន ៩៥០.០០០.០០០៛ សម្រាប់គោលបំណង៖ ១) ពង្រីកបណ្តាញបំពង់ ២) ដំឡើងម៉ូទ័រុញ និងទូបញ្ជា ៣) ដំឡើងប្រព័ន្ធថាមពលព្រះអាទិត្យ ៤) ចំណាយលើពលកម្ម គ្រឿងតំណ និងកែលម្អអាងប្រព្រឹត្តកម្ម និង៥) ចំណាយលើគោលបំណងផ្សេងៗ។

- ២. គម្រោង«សហគមន៍ដឹកនាំទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុ ប្រកបដោយបរិយាប័ន្ន (**CLICR WASH)**» **គាំទ្រដោយអង្គការ EMW** បុគ្គលិកសមាគមបានចូលរួមសម្របសម្រួលជាមួយអង្គការ EMW, CDRI, ISF-UTS ក្នុងការសម្ភាសន៍អាជ្ញាធរមូលដ្ឋានក្នុងសង្កាត់រលាប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។ ការសម្ភាសន៍នេះផ្តោតលើដំណើរការបង្កើតក្រុម និងការអនុវត្តន៍ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ។ កិច្ចសម្ភាសន៍នេះមានអ្នកចូលរួមសរុបចំនួន ៤៧នាក់ ស្រីចំនួន ១៧នាក់។

**៣. គម្រោង«ការពង្រឹងប្រព័ន្ធផែនការគ្រប់គ្រងធនធានទឹក សម្រាប់សេវាកម្មទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុ ប្រកបដោយបរិយាប័ន្ននៅក្នុងប្រទេសកម្ពុជា» គាំទ្រដោយសាកលវិទ្យាល័យ UTS**

➢ សមាគមបានផ្តល់វគ្គបង្វឹកផ្ទាល់ដល់ស្ថានីយទឹកស្អាតចំនួនពីរ (ស្ថានីយផ្គត់ផ្គង់ទឹកស្អាតត្បែងខ្ពស់ និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតលង្វែក) លើប្រធានបទស្តីពី«ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតកម្ពុជា»។ វគ្គបង្វឹកនេះមានអ្នកចូលរួមសរុបចំនួន ១៨នាក់ ស្រីចំនួន ៧នាក់។

## ២.៣ កិច្ចប្រជុំវិសាមញ្ញក្រុមប្រឹក្សាភិបាល

ក្នុងត្រីមាសទី២ សមាគមបានរៀបចំកិច្ចប្រជុំវិសាមញ្ញ តាមរយៈ អនឡាញខល (Zoom Call Meeting) ជាមួយក្រុមប្រឹក្សាភិបាលបានចំនួន ២លើក៖

**លើកទី១៖** ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៤ មានសមាសភាពចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាលចំនួន៩នាក់ (ស្រីចំនួន ២នាក់) ដើម្បីពិភាក្សាទៅលើ៖

១) ការចូលរួមពិធីប្រកាសក្រុមប្រឹក្សាភិបាលរបស់រដ្ឋាករទឹកសាធារណៈ៖ តបតាមការអញ្ជើញរបស់ក្រសួងឧវបន ក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិបានអញ្ជើញចូលរួមពិធីប្រកាសសមាសភាពប្រធានក្រុមប្រឹក្សាភិបាលនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ រដ្ឋាករទឹកស្ទឹងត្រែង រដ្ឋាករទឹកបាត់ដំបង រដ្ឋាករទឹកពោធិ៍សាត់ រដ្ឋាករទឹកកំពត និងរដ្ឋាករទឹកក្រុងស្ទឹងសែន នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤។

២) ការរៀបចំកិច្ចប្រជុំជាមួយសមាជិកតាមប្រព័ន្ធអនឡាញ ដើម្បីចែករំលែកបទពិសោធន៍អំពីក្រុមការងារចុះពិនិត្យនិងវាយតម្លៃស្ថានភាពជាក់ស្តែងរបស់ប្រតិបត្តិករផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតឯកជន៖ **លោក លឹម មិញ** បានស្នើសុំ **លោក ចាន់ ថានី** សមាជិកក្រុមប្រឹក្សាភិបាល និងម្ចាស់ស្ថានីយទឹកស្អាតបហ៊ុយ ចែករំលែកបទពិសោធន៍អំពីការចុះពិនិត្យ និងវាយតម្លៃស្ថានភាពជាក់ស្តែងរបស់ប្រតិបត្តិករផ្តល់សេវាទឹកស្អាតឯកជន ទៅកាន់សមាជិកសមាគម ដើម្បីទទួលបានជាព័ត៌មាន និងជាសារសម្រាប់ប្រតិបត្តិករទាំងអស់ត្រៀមខ្លួនជាមុន។

**លើកទី២៖** ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤ មានសមាសភាពចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាលចំនួន ៩នាក់ (ស្រីចំនួន ២នាក់) ដើម្បីពិភាក្សាស្តីពី «ការធ្វើវិសោធនកម្មគោលនយោបាយសមាជិកភាព (ថ្លៃបង់ប្រាក់សមាជិកភាពប្រចាំឆ្នាំ)»។ បន្ទាប់ពីក្រុមប្រឹក្សាភិបាលបានពិភាក្សាគ្នាយ៉ាងផុលផុស និងធ្វើការពិចារណាយ៉ាងល្អិតល្អន់ក្នុងការកែសម្រួលប្រាក់វិភាគទានសមាជិក។ ជាលទ្ធផល ក្រុមប្រឹក្សាភិបាលបានឯកភាពជាឯកច្ឆន្ទ (៩សំឡេងលើ៩សំឡេង) ក្នុងការកំណត់ថ្លៃប្រាក់សមាជិកភាពប្រចាំឆ្នាំដូចខាងក្រោម៖

| ប្រភេទសមាជិក | តារាងប្រាក់វិភាគទានចាស់ | | តារាងប្រាក់វិភាគទានថ្មី | |
|---|---|---|---|---|
| | ចំនួនតំណ | ចំនួនប្រាក់វិភាគទាន | ចំនួនតំណ | ចំនួនប្រាក់វិភាគទាន |
| សមាជិកអាជីព | ពី០ ដល់ ៧៥០តំណ | $២០០ | ពី០ ដល់ ៧៥០តំណ | $២០០ |
| | ពី៧៥១តំណ ដល់ ១៥០០តំណ | $២៥០ | ពី៧៥១តំណ ដល់ ១៥០០តំណ | $២៥០ |
| | ពី១៥០១តំណ ដល់ ៣០០០តំណ | $៣៥០ | ពី១៥០១តំណ ដល់ ៣០០០តំណ | $៣៥០ |
| | ពី៣០០១តំណ ដល់ ៦០០០តំណ | $៥០០ | ពី៣០០១តំណ ដល់ ៦០០០តំណ | $៥០០ |
| | ពី៦០០១ ឡើងទៅ | $៧០០ | ពី៦០០១តំណ ដល់ ១០០០០តំណ | $៧០០ |
| | | | ពី១០០០១តំណ ដល់ ១៥០០០តំណ | $១០០០ |
| | | | ពី១៥០០១តំណ ដល់ ២០០០០តំណ | $១៥០០ |
| | | | ពី២០០០១តំណ ដល់ ២៥០០០តំណ | $២០០០ |
| | | | ពី២៥០០១តំណ ដល់ ៣០០០០តំណ | $២៥០០ |
| | | | ពី៣០០០១តំណ ឡើងទៅ | $៣០០០ |
| សមាជិកគាំទ្រ | ជារូបវន្តបុគ្គល | $១០០ | ជារូបវន្តបុគ្គល | $១០០ |
| | ជារូបវន្តបុគ្គលដែលផ្តល់សេវា | $៣០០ | ជារូបវន្តបុគ្គលដែលផ្តល់សេវា | $៣០០ |
| | ជានិតិបុគ្គល(សញ្ជាតិខ្មែរ) | $២៥០ | ជានិតិបុគ្គល(សញ្ជាតិខ្មែរ) | $២៥០ |
| | ជានិតិបុគ្គល(សញ្ជាតិបរទេស) | $៣៥០ | ជានិតិបុគ្គលបរទេស(សញ្ជាតិបរទេស) | $៣៥០ |

## ៣. ការខារស្ថលសមាគម

### ៣.១ ការចូលជាសមាជិកថ្មីរបស់សមាគម

ក្នុងត្រីមាសទី២ នៃឆ្នាំ២០២៤ សមាគមបានទទួលសមាជិកថ្មីចំនួន ៨ ដែលក្នុងនោះមានសមាជិកអាជីពចំនួន ៣ស្ថានីយ និងសមាជិកគាំទ្រចំនួន ៥ក្រុមហ៊ុន ដូចមានរាយនាមខាងក្រោម៖

| ល.រ | ឈ្មោះស្ថានីយផ្គត់ផ្គង់ទឹកស្អាត | ខេត្ត |
|---|---|---|
| ១ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សន្តិភាព | បាត់ដំបង |
| ២ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្រុកកំពង់រោទិ៍ | ស្វាយរៀង |
| ៣ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ត្រពាំងក្រញូង | តាកែវ |
| សរុប៖ ៣ ស្ថានីយផ្គត់ផ្គង់ទឹកស្អាត | | |

| ល.រ | ឈ្មោះសមាជិកគាំទ្រ |
|---|---|
| ១ | ក្រុមហ៊ុន ជេអេចអេសវ៉ាយ (ខេមបូឌា) ផាយឡាញ ឯ.ក |
| ២ | ក្រុមហ៊ុន អាយ.អេស.អ៊ី.អេ អេនជីនារីង ឯ.ក |
| ៣ | ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា (FTB) |
| ៤ | Molecor South East Asia |
| ៥ | ធនាគារប្រៃសណីយ៍កម្ពុជា ក.អ |
| សរុប៖ ៥ ក្រុមហ៊ុន | |

## ៣.២ កិច្ចប្រជុំថ្នាក់តំបន់

នៅក្នុងត្រីមាសទី២ សមាគមបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់ចំនួនពីរលើក ក្នុងគោលបំណង៖

១. ស្តាប់សំឡេងរបស់សមាជិក និងស្វែងរកដំណោះស្រាយជូនសមាជិក
២. ផ្សព្វផ្សាយពី«គម្រោងហិរញ្ញប្បទានធនាគារសហគ្រាសធុនតូច និងមធ្យម» និងការជ្រើសរើសប្រតិបត្តិករសម្រាប់គម្រោង«ការកែលម្អលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅកម្ពុជា ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត»
៣. បង្កើនទំនាក់ទំនងជាមួយមន្ទីរ ឧវបន សមាជិកសមាគម និងដៃគូអភិវឌ្ឍន៍
៤. បច្ចុប្បន្នភាពពីសមាគមច្បាប់គតិយុត្តទាក់ទងទៅនឹងវិស័យទឹកស្អាត និងការចែករំលែកចំណេះដឹងបទពិសោធន៍ ព័ត៌មាន និងបច្ចេកវិទ្យាថ្មីៗ។

១. **លើកទី១៖** ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ សមាគមបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់សម្រាប់ប្រតិបត្តិករជាសមាជិកសមាគម មកពីខេត្តព្រះវិហារ កំពង់ធំ ព្រៃវែង មណ្ឌលគីរី ក្រចេះ ត្បូងឃ្មុំ និងកំពង់ចាម។ កិច្ចប្រជុំបានរៀបចំនៅសណ្ឋាគារភ្នំប្រុស ក្រុងកំពង់ចាម ខេត្តកំពង់ចាម ក្រោមអធិបតីភាព **លោក ពូន រុន** ប្រធានមន្ទីរ ឧវបន ខេត្តកំពង់ចាម និង **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាលសមាគម។ កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ៧៩នាក់(ស្រី ១៧នាក់) រួមមាន៖ ថ្នាក់ដឹកនាំ និងមន្ត្រីនៃមន្ទីរ ឧវបន ខេត្តកំពង់ចាម អង្គការ Water.org ក្រុមប្រឹក្សាភិបាល បុគ្គលិកសមាគម តំណាងធនាគារ ក្រុមហ៊ុនចំនួន៦ ព្រមទាំងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ៤៤ស្ថានីយដែលជាសមាជិកសមាគម។ ក្នុងកិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភធំពីអង្គការ Water.org និងសហការឧបត្ថម្ភពីក្រុមហ៊ុនទាំង ៦រួមមាន៖ ១) ក្រុមហ៊ុន TCU ២) ក្រុមហ៊ុន Phnom Penh Plastic ៣) ក្រុមហ៊ុន X-Water ៤) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ AMK ៥) ក្រុមហ៊ុន UPG Pipe និង ៦) ក្រុមហ៊ុន LESSO។



*រូបភាពទី២៖ ការថតរូបអនុស្សាវរីយ*

២. **លើកទី២៖** ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ សមាគមបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់សម្រាប់ប្រតិបត្តិករជាសមាជិកសមាគម មកពីខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ និងឧត្តរមានជ័យ។ កិច្ចប្រជុំនេះបានរៀបចំនៅសណ្ឋាគារ ខេមរាបាត់ដំបង១ ខេត្តបាត់ដំបងក្រោមអធិបតីភាព **លោក រស់ វិសិទ្ធ** អនុប្រធានមន្ទីរ

ឧបេន ខេត្តបាត់ដំបង និង **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាលសមាគម។ កិច្ចប្រជុំនេះមានអ្នកចូលរួមសរុបចំនួន ៨៦នាក់(ស្រី ១៨នាក់) រួមមានៈ ថ្នាក់ដឹកនាំ និងមន្ត្រីនៃមន្ទីរ ឧបេន ខេត្តបាត់ដំបង ក្រុមប្រឹក្សាភិបាលបុគ្គលិកសមាគម តំណាងធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ៣៩ស្ថានីយដែលជាសមាជិកសមាគម។

ក្នុងកិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភធំពីអង្គការ Water.org និងសហការឧបត្ថម្ភពីៈ ១) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ AMK ២) ក្រុមហ៊ុន TCU ៣) ក្រុមហ៊ុន X-Water ៤) ក្រុមហ៊ុន KCRI ៥) ក្រុមហ៊ុន TECHZONE Plus ៦) ក្រុមហ៊ុន LESSO និង ៧) ក្រុមហ៊ុន CHIP MONG។



*រូបភាពទី៣៖ ការចូលរួមរបស់សិក្ខាកាមក្នុងកិច្ចប្រជុំថ្នាក់តំបន់*

នៅរសៀលថ្ងៃដដែល សមាគមបានសម្របសម្រួលសមាជិកដែលបានចូលរួមនៅក្នុងកិច្ចប្រជុំថ្នាក់តំបន់ក្នុងខេត្តបាត់ដំបងទៅទស្សនកិច្ចសិក្សាស្វែងយល់ពីការគ្រប់គ្រងអាជីវកម្ម និងបច្ចេកទេសផលិតទឹកស្អាតនៅរដ្ឋាករទឹកបាត់ដំបង។



*រូបភាពទី៤៖ ទស្សនកិច្ចសិក្សាទៅកាន់រោងចក្រផលិតទឹកស្អាតនៃរដ្ឋាករទឹកបាត់ដំបង(ការលាងអាងខ្សាច់)*



*រូបភាពទី៥៖ សិក្ខាកាមក្នុងកិច្ចប្រជុំថ្នាក់តំបន់នៅខេត្តបាត់ដំបង បានចូលរួមស្តាប់បទបង្ហាញរបស់តំណាងរដ្ឋាករទឹកបាត់ដំបង*

## ៣.៣ កិច្ចគាំពារសមាជិក

ក្នុងត្រីមាសទី២ ឆ្នាំ២០២៤ សមាគមបានគាំទ្រ និងសម្របសម្រួលកិច្ចប្រជុំដោះស្រាយបញ្ហារបស់សមាជិកបានចំនួន ១ករណី។

ថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៤ សមាគមបានសហការជាមួយ មន្ទីរ ឧវបន ខេត្តតាកែវ និងអាជ្ញាធរមូលដ្ឋានបានចុះទៅប្រជុំដោះស្រាយទំនាស់នៃការបូមទឹកបឹងអំពែទុំ។ ស្ថានីយផ្គត់ផ្គង់ទឹកស្អាតលំពង់បានស្នើសុំបូមទឹកបឹងអំពែទុំសម្រាប់ផលិតទឹកស្អាត ដើម្បីផ្គត់ផ្គង់នៅក្នុងសហគមន៍ឃុំលំពង់។ ចំណែកប្រជាពលរដ្ឋចំនួន ៤៨គ្រួសារ នៅភូមិអំពែទុំ ភូមិរវៀង និងភូមិអង្គក្រឡាញ់ នៃឃុំតាំងជួង ស្រុកបាទី ខេត្តតាកែវ ដែលជាអ្នកយកទឹកបឹងអំពែទុំមកធ្វើស្រែប្រាំង។ ទន្ទឹមនេះដែរ ដោយមានការជួយសម្របសម្រួលបន្ថែមពី **លោក ហង្ស វិច្ឆិកាវាស្សី** អភិបាលរងស្រុកបាទី និងសហការី ព្រមទាំងអាជ្ញាធរឃុំលំពង់។ ជាលទ្ធផលភាគីទាំងអស់បានឯកភាពគ្នាទៅលើ ៣ចំណុច៖ ១) អនុញ្ញាត្តិឱ្យស្ថានីយផ្គត់ផ្គង់ទឹកស្អាតលំពង់បូមទឹកជម្រៅមួយម៉ែត្រនៃផ្ទៃទឹកបឹង ២)បើដល់កម្រិតកំណត់មួយម៉ែត្រ និងពេលមានភ្លៀងធ្លាក់គ្រប់គ្រាប់ហើយស្នើឱ្យស្ថានីយ ត្រូវរើម៉ូទ័រ និងទុយោចេញពីបឹង និង៣)ស្នើសុំស្ថានីយជួយផ្តល់ថវិកាចំនួន ៣លានរៀលក្នុងមួយភូមិសម្រាប់ការងារអភិវឌ្ឍន៍នៅក្នុងភូមិ។ មកដល់ពេលបច្ចុប្បន្ន ស្ថានីយផ្គត់ផ្គង់ទឹកស្អាតលំពង់ បានបូមទឹកឆៅពីបឹងអំពែទុំ ដើម្បីយកមកផលិតទឹកស្អាតសម្រាប់ផ្គត់ផ្គង់នៅក្នុងសហគមន៍ឃុំលំពង់រួចរាល់ហើយ។



*រូបភាពទី៦៖ ទិដ្ឋភាពនៃការបូមទឹកឆៅពីបឹងអំពៃទុំ របស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតលំពង់*

## ៣.៤ ការចុះសួរសុខទុក្ខសមាជិក

ក្នុងត្រីមាសទី២ ឆ្នាំ២០២៤នេះ សមាគមបានចុះសួរសុខទុក្ខសមាជិកបានចំនួន ៣លើករួមមាន៖

**លើកទី១៖** ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគមបានជួបសំណេះសំណាល និងសួរសុខទុក្ខម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតឃុំកោះមិត្ត ស្ថិតនៅភូមិកំពង់ត្រុំលើ ឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគមបានសាកសួរព័ត៌មានអំពីដំណើរអាជីវកម្ម ស្តាប់អំពីបញ្ហាក៏ដូចជាសំណូមរបស់ម្ចាស់ស្ថានីយ ដើម្បីយកមកពិភាក្សាក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។



*រូបភាពទី៧៖ ការចុះសួរសុខទុក្ខសមាជិក នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត កោះមិត្ត ខេត្តកំពង់ចាម*

**លើកទី២៖** នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៤ បុគ្គលិកសមាគមបានចុះទៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំចាយមារ ដើម្បីសួរសុខទុក្ខ និងធ្វើការវិភាគគុណភាពទឹកឆៅតាមរយៈការធ្វើជ្យាតេស្ត ដើម្បីកំណត់ប្រភេទ និង

បរិមាណនៃសារធាតុគីមីសម្រាប់យកមកលាយផលិតទឹកស្អាតព្រមទាំងបានផ្តល់ជាអនុសាសន៍ជូនម្ចាស់ស្ថានីយ ដើម្បីឱ្យគាត់កែលម្អកាន់តែប្រសើរឡើង។



*រូបភាពទី៨៖ ការធ្វើជ្យាតេស្តទឹកឆៅ ដើម្បីកំណត់បរិមាណសារធាតុគីមីឱ្យបានត្រឹមត្រូវ នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត កំចាយមារ ខេត្តព្រៃវែង*

**លើកទី៣៖** នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគមបានចុះទៅសំណេះសំណាល និងសួរសុខទុក្ខដល់សមាជិកសមាគមនៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតអូរតាតន់ ដែលមានទីតាំងស្ថិតនៅភូមិអូរគ្រោត ឃុំគារ ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ ក្រោយពីធ្វើការសំណេះសំណាល យើងសង្កេតឃើញថាស្ថានីយគាត់បានជួបប្រទះនូវការខ្វះខាតទឹកសម្រាប់ការផលិតទឹកស្អាតចែកជូនដល់អតិថិជនរបស់គាត់ ដោយសារតែបឹងដែលជាប្រភពទឹកសម្រាប់បូមទឹកឆៅមានការរីងស្ងួត ហើយកំពុងធ្វើការស្តារឡើងវិញ។ នាពេលបច្ចុប្បន្នស្ថានីយគាត់បានទិញទឹកដុំពីស្ថានីយផ្សេងយកមកផ្គត់ផ្គង់ជូនអតិថិជនបានខ្លះៗតែប៉ុណ្ណោះ។ ក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគម បានផ្តល់ជាអនុសាសន៍ជូនគាត់រួមមាន៖ បន្តការស្តារបឹងដើម្បីឆាប់បានទឹកយកមកផ្គត់ផ្គង់ដល់អតិថិជនរបស់គាត់ រៀបចំអាងប្រព្រឹត្តិកម្មឱ្យមានលក្ខណៈសមស្រប បើអាចបង្កើនចំនួននៃការទិញទឹកដុំពីស្ថានីយផ្សេងក្នុងពេលដែលស្ថានីយគាត់កំពុងជួបប្រទះនូវការខ្វះខាតទឹកដូចសព្វថ្ងៃ។



*រូបភាពទី៩៖ ការចុះសួរសុខទុក្ខសមាជិក នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតអូរតាតន់ ខេត្តបាត់តំបង*

## ៣.៥ ជំនួយបច្ចេកទេសដល់សមាជិក

ក្នុងត្រីមាសទី២ ឆ្នាំ២០២៤ សមាគមបានផ្តល់ជំនួយបច្ចេកទេសជូនសមាជិកដូចខាងក្រោម៖

- ❖ ធ្វើជ្យាតេស្តទឹកឆៅឱ្យជូនសមាជិកបានចំនួន ៤ស្ថានីយ ដើម្បីកំណត់បរិមាណសារធាតុគីមីដែលត្រូវប្រើសម្រាប់ផលិតទឹកស្អាតឱ្យបានត្រឹមត្រូវសម្រាប់៖
  ១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំចាយមារ
  ២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតផ្សារស្លាបលែង
  ៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតហ៊ីង ហុង
  ៤. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតជំរឹផ្ទង



*រូបភាពទី១០៖ ការធ្វើតេស្តគុណភាពទឹកឆៅ ដល់លោក សួស ពុយ ម្ចាស់ស្ថានីយទឹកស្អាត ស្លាបលែង*

- ❖ វិភាគគុណភាពទឹកឆៅ លើប៉ារ៉ាម៉ែត្រ ដែក ម៉ង់កាណេស ភាពរឹងនៃទឹក ប៉េហាស ជូនដល់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតតាំងក្រសាំង។
- ❖ ផ្តល់ការប្រឹក្សាយោបល់អំពីដំណើរការផលិតទឹកបាន ៣ស្ថានីយ៖
  ១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតកែវសើមា
  ២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតព្រៃប្រស់
  ៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតលំពង់

## ៣.៦ ការចែករំលែកព័ត៌មានជូនសមាជិក

ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៤ សមាគមបានដឹកនាំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ Zoom Call ស្តីពីការត្រៀមរៀបចំស្ថានីយ និងឯកសារពាក់ព័ន្ធនានា មុនពេលក្រុមការងារក្រសួង ឧបន ចុះវាយតម្លៃស្ថានភាពជាក់ស្តែងនៃការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត របស់ប្រតិបត្តិករទឹកស្អាតឯកជន។ កិច្ចប្រជុំនេះ មានការចូលរួមពី សមាជិកក្រុមប្រឹក្សាភិបាល និងបុគ្គលិកសមាគម ព្រមទាំងប្រតិបត្តិករទឹកស្អាតឯកជនដែលជាសមាជិកសមាគម នៅខេត្តកណ្តាល និងខេត្តប៉ៃលិន សរុបមានចំនួន ២៩នាក់។

នៅក្នុងកិច្ចប្រជុំនេះ សមាគមបានធ្វើបទបង្ហាញ ព្រមទាំងផ្តល់ឱកាសឱ្យអ្នកចូលរួមធ្វើការពិភាក្សាគ្នាពី ការបំពេញបញ្ជីគោលការចុះវាយតម្លៃស្ថានភាពជាក់ស្តែងនៃការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតរួមមាន៖ ១) ព័ត៌មានទូទៅរបស់ប្រតិបត្តិករ ២) ការចុះពិនិត្យ និងលទ្ធផល ៣) ការវិនិយោគ និងស្ថានភាពអាជីវកម្ម ៤) ការអនុវត្តលក្ខខណ្ឌ និង និរន្តភាពសេវាកម្ម និង ៥)សំណូមពរទូទៅរបស់ប្រតិបត្តិករ។




*រូបភាពទី១១៖ កិច្ចប្រជុំតាមប្រព័ន្ធអនឡាញតាម Zoom Call*

## ៣.៧ ទស្សនកិច្ចសិក្សា

### ៣.៧.១ ទស្សនកិច្ចសិក្សាក្នុងប្រទេស

នៅក្នុងត្រីមាសទី២ ឆ្នាំ២០២៤ សមាគមបានរៀបចំទស្សនកិច្ចសិក្សាក្នុងប្រទេសសម្រាប់សមាជិកបានចំនួន ២លើកមានដូចខាងក្រោម៖

**លើកទី១៖** ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២៤ ទស្សនកិច្ចសិក្សានៅក្រុមហ៊ុន ខោលបុលទឹកស្អាត ឯ.ក និង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ-រោងចក្រផលិតទឹកស្អាតម្លេច ដើម្បីសិក្សារៀនសូត្រពីប្រភពទឹកអាងប្រព្រឹត្តកម្ម និងការគ្រប់គ្រងអាជីវកម្មដែលមានលក្ខណៈជាក្រុមហ៊ុន និងបានទៅសិក្សារៀនសូត្របច្ចេកទេសពីរបៀបនៃការរៀបចំស្ថានីយបូមទឹកឆៅ អាងប្រព្រឹត្តកម្មដោយស្វ័យប្រវត្តិ របៀបរៀបចំបន្ទប់ពិសោធន៍សម្រាប់វិភាគគុណភាពទឹកស្អាត និងប្រព័ន្ធទូបញ្ជាម៉ូទ័រ។ ជាងនេះទៅទៀត បានកសាងទំនាក់ទំនងល្អរវាងសមាជិក និងសមាគម ព្រមទាំងទទួលបាននូវអារម្មណ៍ស្រស់ថ្លាជាមួយរមណីយដ្ឋានធម្មជាតិម្លេចផងដែរ។ ដំណើរទស្សនកិច្ចសិក្សានេះមានអ្នកចូលរួមចំនួន ២៥នាក់ (ស្រីចំនួន ៤នាក់) មកពី១៤ស្ថានីយ និង ៥ក្រុមហ៊ុន។



*រូបភាពទី១២៖ ទស្សនកិច្ចសិក្សានៅក្រុមហ៊ុន ខោល ប៊ុល ទឹកស្អាត*



*រូបភាពទី១៣៖ ទស្សនកិច្ចនៅអាងប្រព្រឹត្តកម្ម រដ្ឋាករទឹក ភ្នំពេញ (រោងចក្រផលិតទឹកស្អាត ម្លេច)*

**លើកទី២៖** ថ្ងៃទី៣០-៣១ ខែឧសភា ឆ្នាំ២០២៤ ទស្សនកិច្ចសិក្សានៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត ពកត្របែក និងរដ្ឋាករទឹកកំពត ដើម្បីសិក្សាស្វែងយល់ពី ចង្វាក់ផលិតកម្ម និងការផ្គត់ផ្គង់ទឹកស្អាត ព្រមទាំងការចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក ព្រមទាំងស្វែងយល់បន្ថែមអំពីចង្វាក់ផលិត បច្ចេកវិទ្យាថ្មីៗ ព្រមទាំងការរៀបចំស្ថានីយបូមទឹកឆៅ ដើម្បីយកទៅកែលម្អ និងអភិវឌ្ឍនៅស្ថានីយរៀងៗខ្លួន។ នៅក្នុងទស្សនកិច្ចសិក្សា និងដំណើរកំសាន្តនេះ មានសមាជិកចំនួន ១៤នាក់ (ស្រី ៣នាក់) មកពី ១១ស្ថានីយ និង ២ក្រុមហ៊ុនបានចូលរួម។




*រូបភាពទី១៤៖ ការថតរូបអនុស្សាវរីយ៍នៅស្ថានីយទឹកស្អាត ពកត្របែក*



*រូបភាពទី១៥៖ រូបភាពនៅក្នុងបន្ទប់ពិសោធន៍ រោងចក្រទឹកស្អាត កំពត*

**លើកទី៣៖** ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ ទស្សនកិច្ចសិក្សានៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត បហ៊ុយ ដើម្បីសិក្សាស្វែងយល់ពី ចង្វាក់ផលិតកម្ម ការផ្គត់ផ្គង់ទឹកស្អាត និងការចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក ព្រមទាំងស្វែងយល់បន្ថែមអំពីនវានុវត្តន៍ និង បច្ចេកវិទ្យាថ្មីៗ ដែលស្ថានីយបហ៊ុយ បានដំឡើងរៀបចំដូចជា៖ (ការរៀបចំស្ថានីយបូមទឹកឆៅ និងការដំឡើងរហាត់ទឹកដើម្បីបង្កើតចរន្តអគ្គិសនីយកមកប្រើប្រាស់ ។ នៅក្នុងទស្សនកិច្ចសិក្សានេះមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាល បុគ្គលិក និងសមាជិកសមាគម ចំនួន ១៨នាក់ (ស្រី ៦នាក់) មកពី ៩ស្ថានីយ។



*រូបភាពទី១៦៖ រូបភាពហោត់ទឹកបង្កើតថាមពលអគ្គិសនី និងរោងចក្រផលិតទឹកស្អាត*

### ៣.៧.២ ទស្សនកិច្ចសិក្សាក្រៅប្រទេស

នៅក្នុងត្រីមាសទី២ ឆ្នាំ២០២៤ សមាគមបានរៀបចំទស្សនកិច្ចសិក្សាក្រៅប្រទេស បានចំនួន ២លើក មានដូចខាងក្រោម៖

**លើកទី១៖** តបតាមការអញ្ជើញរបស់សមាគមទឹកម៉ាឡេស៊ី (MWA) នោះអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ... ឧបន មន្ទីរឧបន ខេត្តកំពង់ស្ពឺ និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ព្រមទាំងសមាជិកសមាគមសរុបចំនួន ២១នាក់(ស្រី ៨នាក់) ក្នុងនោះសមាជិកសមាគមមានចំនួន ១៧នាក់(ស្រីចំនួន ៧នាក់) មកពី ១៤ ស្ថានីយ ចូលរួមក្នុងសន្និសីទ និងពិព័រណ៍ទឹកលើកទី១៣របស់ ASIA WATER ចាប់ពីថ្ងៃទី២៣-២៥ ខែមេសា ឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលសន្និបាតកូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។



*រូបភាពទី១៧៖ ការចូលរួមក្នុងសន្និសីទ និងពិព័រណ៍ទឹកលើកទី១៣*

នៅរសៀលថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤ **លោក លឹម មិញ** នាយកប្រតិបត្តិសមាគម បានចូលរួមជាវាគ្មិនក្នុងកម្មវិធីជជែកពិភាក្សា«Regional Water Industry Expert Dialogue on Navigating the Water » ដោយបានចែករំលែកពីស្ថានភាពផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា បញ្ហាប្រឈម ដំណោះស្រាយ និងឱកាសវិនិយោគនានានៅប្រទេសកម្ពុជា។




*រូបភាពទី១៨៖ ការចូលរួមជាវាគ្មិនក្នុងកម្មវិធីជជែកពិភាក្សា «Regional Water Industry Expert Dialogue on Navigating the Water»*

**លើកទី២៖** តបតាមការអញ្ជើញរបស់អង្គការ CAPRED និង Water.org ក្រសួង ឧវបន ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ ធនាគារសហគ្រាសធុនតូច និងមធ្យម សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ប្រតិបត្តិករជាស្ត្រីដែលជាសមាជិកសមាគម អង្គការ CAPRED និង Water.org ដែលសរុបទាំងអស់មានចំនួន ២៦នាក់ (ស្រី ១៣នាក់) បានចូលរួមក្នុងវេទិកាទឹកពិភពលោកលើកទី១០ ចាប់ពីថ្ងៃទី ១៩ - ២៥ ខែឧសភា ឆ្នាំ២០២៤ នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី។




*រូបភាពទី១៩៖ តំណាងសមាគមចូលរួមក្នុងវេទិកាទឹកពិភពលោកលើកទី១០ ប្រទេសឥណ្ឌូនេស៊ី*

គោលបំណងនៃវេទិកាទឹកពិភពលោកលើកទី១០ផ្តោតទៅលើ៖

១) ការលើកកម្ពស់សារៈសំខាន់នៃទឹកនៅលើរបៀបវារៈនយោបាយពិភពលោក ដោយប្រមូលផ្តុំអ្នកធ្វើសេចក្តីសម្រេចចិត្ត អ្នកជំនាញទឹក និងអ្នកពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីបញ្ហាទឹកសំខាន់ៗ។
២) តាមរយៈការជំរុញកិច្ចសន្ទនា និងកិច្ចសហការរវាងភាគីពាក់ព័ន្ធនានា វេទិកានេះមានគោលបំណងស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមទឹកជាសកល និង ៣) ការពិភាក្សា និងកិច្ចព្រមព្រៀងដែលសម្រេចបានក្នុងវេទិកានេះមានគោលបំណងជំរុញសកម្មភាពជាក់ស្តែងឆ្ពោះទៅរកការសម្រេចបាននូវសុវត្ថិភាពទឹក និងការអនុវត្តការគ្រប់គ្រងទឹកប្រកបដោយនិរន្តរភាព។



*រូបភាពទី២០៖ តំណាងក្រសួងទាំង៣បានចូលរួមក្នុងវេទិកាទឹកពិភពលោកលើកទី១០ នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី*



*រូបភាពទី២១៖ គណប្រតិភូកម្ពុជា ចូលរួមក្នុងវេទិកាទឹកពិភពលោកលើកទី១០ នៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី*

## ៤. កិច្ចសហប្រតិបត្តិការ

### ៤.១ កិច្ចប្រជុំរវាងសមាគម និងមន្ទីរ ឧវបន ខេត្តកំពង់ចាម

នៅរសៀលថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាល បុគ្គលិកសមាគម បានជួបប្រជុំជាមួយលោកប្រធាន និងលោកអនុប្រធានមន្ទីរ ឧវបន ខេត្តកំពង់ចាម ដើម្បីពិភាក្សាពីការងារ និងកិច្ចសហការរវាងមន្ទីរ និងសមាគម ដែលមានអ្នកចូលរួមសរុបចំនួន ៨នាក់ (ស្រី ៣នាក់)។ របៀបវារៈនៃកិច្ចប្រជុំរួមមាន៖

១. បង្កើនកិច្ចទំនាក់ទំនងគ្នារវាងមន្ទីរ ឧវបន ខេត្តកំពង់ចាម និងសមាគម

២. ពិភាក្សាអំពីបញ្ហារបស់ប្រតិបត្តិករ និងសិក្សាពីដំណោះស្រាយដែលបានអនុវត្តកន្លងមក

៣. សមាគមស្នើសុំឱ្យមានកិច្ចប្រជុំប្រចាំត្រីមាសរវាងប្រតិបត្តិករក្នុងខេត្ត និងឯកឧត្តមអភិបាលខេត្ត/អភិបាលរងខេត្ត និងមន្ទីរ ឧវបន

៤. សមាគមស្នើសុំអញ្ជើញ លោកប្រធានមន្ទីរ ឧវបន ចូលរួមជាគណអធិបតីបើកក្នុងកិច្ចប្រជុំថ្នាក់តំបន់។

ជាលទ្ធផល លោកប្រធាន និងអនុប្រធានមន្ទីរ ឧវបន រីករាយក្នុងការផ្តល់កិច្ចសហការជាមួយសមាគមក្នុងការដោះស្រាយបញ្ហារបស់ប្រតិបត្តិករជាសមាជិកសមាគម ឯកភាពនិងគាំកិច្ចសហការជាមួយសមាគមក្នុងការរៀបចំកិច្ចប្រចាំប្រជុំត្រីមាសជាមួយអាជីវករក្នុងខេត្តកំពង់ចាម។



*រូបភាពទី២២៖ កិច្ចប្រជុំរវាងសមាគម និងមន្ទីរ ឧវបន ខេត្តកំពង់ចាម*

## ៤.២ សិក្ខាសាលាស្តីពី «ការសិក្សាលើកទី១ អំពីប្រព័ន្ធគ្រប់គ្រងបណ្តាញ»

ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤ បុគ្គលិកសមគមចំនួន ៣នាក់ ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងសិក្ខាសាលាស្តីពី **«ការសិក្សាលើកទី១ អំពីប្រព័ន្ធគ្រប់គ្រងបណ្តាញ»** នៅសាលប្រជុំរដ្ឋាករទឹកស្វយ័តសៀមរាប ដែលរៀបចំដោយក្រុមហ៊ុន GOCRAFT ក្រោមកិច្ចសហការរៀបចំជាមួយក្រសួង ឧវបន និងសមាគម KOWBA។ សមាសភាពអ្នកចូលរួម អញ្ជើញមកពីក្រសួង ឧវបន រដ្ឋាករទឹកសាធារណៈ (ស្ទោង សៀមរាប ស្វាយរៀង និងស្ទឹងត្រែង) ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ១០ស្ថានីយ មកពីខេត្តចំនួន ៥ សមាគម CWA ក្រុមហ៊ុន KOWBA និងក្រុមហ៊ុន GOCRAFT។






*រូបភាពទី២៣៖ សិក្ខាសាលាស្តីពី «ការសិក្សាលើកទី១ អំពីប្រព័ន្ធគ្រប់គ្រងបណ្តាញ»*

# ៥. ការខារគម្រោង

## ៥.១ ការកែលម្អលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅកម្ពុជាដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត

### ៥.១.១ ការពង្រឹងសមត្ថភាពប្រតិបត្តិករលើផ្នែកបច្ចេកទេស

នៅក្នុងត្រីមាសទី២ ឆ្នាំ២០២៤ សមាគមបានបន្តតាមដានការតេស្តគុណភាពទឹកស្អាតរបស់សមាជិកក្នុងគម្រោង និងបានផ្តល់យោបល់កែតម្រូវលើការតេស្តគុណភាពទឹកស្អាតលើប៉ារ៉ាម៉ែត្រប្រចាំថ្ងៃជូនសមាជិក។

### ៥.១.២ ការពង្រឹងសមត្ថភាពប្រតិបត្តិករលើប្រព័ន្ធគណនេយ្យ

សមាគមបានសម្របសម្រួលការកិច្ចជួបប្រជុំរវាងប្រតិបត្តិករនៃម្ចាស់ស្ថានីយទឹកស្អាតស្វាយជ្រះនិងក្រុមហ៊ុន EAST WING AUTIDTING & CONSULTING CO., LTD (EW) និងក្រុមហ៊ុន E-Water ដើម្បីពិភាក្សាស្វែងរកដំណោះស្រាយក្នុងការកត់ត្រាទិន្នន័យហិរញ្ញវត្ថុទៅក្នុងប្រព័ន្ធ E-Water។ ជាលទ្ធផល ប្រតិបត្តិករនឹងធ្វើការជាមួយក្រុមហ៊ុន EW ដើម្បីកត់ត្រាទិន្នន័យហិរញ្ញវត្ថុទៅក្នុងកម្មវិធីគណនេយ្យ E-Water នៅដើមខែកក្កដា ឆ្នាំ២០២៤។




*រូបភាពទី២៤៖ កិច្ចប្រជុំតាមអនឡាញ*

ក្រុមហ៊ុន EW កំពុងធ្វើការជាមួយប្រតិបត្តិករចំនួនបួនផ្សេងទៀតដើម្បីប្រមូលឯកសារហិរញ្ញវត្ថុរបស់ពួកគេសម្រាប់ការបើកសមតុល្យសម្រាប់ឆ្នាំ២០២២។

### ៥.១.៣ ការគាំទ្រលើការងារស្នូលរបស់សមាគម

នៅក្នុងត្រីមាសទី២នេះ គម្រោងបានគាំទ្របន្ថែមដល់កិច្ចប្រជុំថ្នាក់តំបន់ចំនួនពីរគឺនៅខេត្តកំពង់ចាម និងខេត្តបាត់ដំបង។ ជាលទ្ធផលនៃកិច្ចប្រជុំ សមាជិកបានរៀនសូត្របន្ថែមអំពីតួនាទី និងការទទួលខុសត្រូវរបស់ប្រតិបត្តិករដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត និងប្រកាសអនុញ្ញាត ព្រមទាំងបានទទួល ចំណេះដឹងថ្មីៗលើបច្ចេកវិទ្យាក្នុងវិស័យទឹកស្អាត លក្ខខណ្ឌនានាក្នុងការទទួលបានហិរញ្ញប្បទាន និងលក្ខខណ្ឌនានាដើម្បីចូលរួមសិក្សាផែនការមេដែលគាំទ្រដោយអង្គការ Water.org ផងដែរ។

### ៥.១.៤ កិច្ចប្រជុំជាមួយស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍

នៅក្នុងត្រីមាសទី២ នេះគម្រោងបានអនុវត្តសកម្មភាពជំរុញការទទួលបានហិរញ្ញប្បទានសម្រាប់វិស័យទឹកស្អាតដូចខាងក្រោម៖

១. ចូលរួមក្នុងកិច្ចពិភាក្សាតុមូលស្តីពី«**ការលើកកម្ពស់វិស័យសម្រាប់លទ្ធភាពទទួលបានទឹកស្អាតដោយសមធម៌នៅកម្ពុជា**» នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៤ ដែលសហការរៀបចំដោយ ក្រសួង ឧវបន ធនាគារពិភពលោក និងអង្គការ Water.org។ កិច្ចពិភាក្សានេះមានគោលបំណង៖ ១). បង្កើតការយល់ដឹងរួមអំពីតម្រូវការទូទៅ និងបញ្ហាប្រឈមដែលប្រតិបត្តិករទឹកឯកជនជួបប្រទះ ក៏ដូចជាការរួមចំណែករបស់ពួកគេក្នុងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពផ្គត់ផ្គង់ទឹកនៅក្នុងប្រទេស។ ២). ដើម្បីចែករំលែកព័ត៌មានលម្អិតនៃកម្មវិធី ឬគម្រោងដែលកំពុងដំណើរការ (រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍) ដោះស្រាយតម្រូវការ និងបញ្ហាប្រឈមដែលបានកំណត់ដោយប្រតិបត្តិករទឹកឯកជនប្រឈមមុខ និងស្វែងរកឱកាសសម្រាប់កិច្ចសហប្រតិបត្តិការ និង ៣). ដើម្បីស្វែងរកគំរូច្នៃប្រឌិត រួមទាំងយុទ្ធសាស្ត្រហិរញ្ញវត្ថុ និងការ វិនិយោគដែលអាចជំរុញកំណើនប្រកបដោយនិរន្តរភាពនៅក្នុងវិស័យផ្គត់ផ្គង់ទឹក។ ក្នុងកិច្ចពិភាក្សានោះដែរសមាគមបានចែករំលែកពីបញ្ហាប្រឈមរបស់ប្រតិបត្តិករ និងតួនាទីរបស់សមាគម។

២. គាំទ្រប្រតិបត្តិករចំនួន ១ស្ថានីយ ដើម្បីរៀបចំប្រវត្តិសង្ខេបនៃការផ្គត់ផ្គង់ទឹកស្អាត និងរបាយការណ៍ហិរញ្ញវត្ថុ ហើយដាក់ជូនក្រុមការងារ Water Equity ដើម្បីពិនិត្យ និងសិក្សាលើគម្រោងកម្ចី។ ទន្ទឹមគ្នានេះដែរគម្រោងបានសម្របសម្រួលកិច្ចប្រជុំរវាងប្រតិបត្តិករនោះ ជាមួយក្រុមការងារ Water Equity នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៤ ដើម្បីពិភាក្សាលម្អិតបន្ថែមអំពីសំណើកម្ចីរបស់ស្ថានីយ។ ជាលទ្ធផល ក្រុមការងារ Water Equity បានសួរសំណួរបន្ថែមដើម្បីបញ្ជាក់ និងផ្តល់ព័ត៌មានអំពីប្រាក់កម្ចីដូចជា ការប្រាក់កម្ចីប្រចាំឆ្នាំប្រហែល ១៤% រយៈពេលកម្ចី ១០ឆ្នាំ និងការទូទាត់សងប្រចាំឆ្នាំ។ ដូច្នេះ ស្ថានីយនោះសម្រេចចិត្តមិនយកប្រាក់កម្ចីនេះទេ ប៉ុន្តែគាត់នៅតែចង់សិក្សាបន្តអំពីមូលនិធិ Water Equity បន្ថែមនាពេលខាងមុខ។

៣. ជួបជាមួយមន្ត្រីធនាគារ SME នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២៤ ដើម្បីពិភាក្សាអំពីកិច្ចសហការរវាងសមាគម និងធនាគារ។ ក្នុងនោះដែរសមាគមបានស្នើសុំធនាគារ SME ដើម្បីធ្វើការពិចារណា៖
   - ក. ស្នើសុំបង្កើនទំហំកម្ចីរហូតដល់ ៣លានដុល្លារ សម្រាប់វិស័យទឹកស្អាត
   - ខ. ស្នើសុំដំឡើងរយៈពេលកម្ចីពី រហូតដល់ ១៥ឆ្នាំ
   - គ. ស្នើសុំកែសម្រួលការទូទាត់សងតាមរដូវកាល ដែលឆ្លុះបញ្ចាំងពីលំហូរសាច់ប្រាក់របស់ប្រតិបត្តិករ
   - ឃ. ស្នើសុំអនុវត្តរយៈពេលអនុគ្រោះសម្រាប់ប្រតិបត្តិករ ដែលទើបតែបង្កើតស្ថានីយថ្មីៗ
   - ង. ជំរុញការសិក្សាកម្ចីរបស់ប្រតិបត្តិករឱ្យបានយ៉ាងឆាប់រហ័ស
   - ច. ចែករំលែករបាយការណ៍ទិដ្ឋភាពទូទៅនៃប្រាក់កម្ចីរបស់សមាជិកសមាគម ជាមួយ SME Bank
   - ឆ. កែសម្រួលខ្លឹមសារបទបង្ហាញជូនប្រតិបត្តិករនៅក្នុងកិច្ចប្រជុំថ្នាក់តំបន់របស់សមាគមជាពិសេសសម្រាប់វិស័យទឹក( ឧទាហរណ៍៖ ដំណើរការស្នើសុំកម្ចីពីដើមដល់ចប់ តម្រូវការសេវាផ្សេងៗ ដំណើរការកម្ចី និងឯកសាររបាយការណ៍ហិរញ្ញវត្ថុ...)។



*រូបភាពទី ២៥៖ ជំនួបរវាងក្រុមការងារធនាគារ SME និងសមាគម*

៤. លើសពីនេះទៀត សមាគម និងអង្គការ Water.org បានជ្រើសរើសក្រុមហ៊ុនទីប្រឹក្សា ដើម្បីរៀបចំផែនការមេសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត និងជ្រើសរើសប្រតិបត្តិករចំនួន៦ស្ថានីយ ដើម្បីចូលរួមក្នុងគម្រោងសិក្សាផែនការមេនេះផងដែរ។ គោលបំណងសំខាន់នៃការសិក្សានេះ គឺបង្កើតផែនការមេអាជីវកម្មចំនួន៦ ដោយមានផែនការវិនិយោគច្បាស់លាស់។ ជាលទ្ធផល ក្រុមការងារបានជ្រើសរើសក្រុមហ៊ុន iSEA ជាក្រុមហ៊ុនផ្តល់សេវាកម្មទីប្រឹក្សា និងជ្រើសរើសបានសមាជិកចំនួន ៦ស្ថានីយដូចជា៖

១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ
២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សូទ្រនិគម ខេត្តសៀមរាប
៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ចំការលើ ខេត្តកំពង់ចាម
៤. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ
៥. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សាលាលេខ៥ ខេត្តកំពង់ឆ្នាំង
៦. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កំពង់ចំលង ខេត្តកណ្តាល

៥. ក្រុមការងាររបស់អង្គការ Water.org និង សមាគម បានចុះពិនិត្យផ្ទាល់ទៅកាន់ ៥ស្ថានីយ ក្នុងគោលបំណងផ្ទៀងផ្ទាត់ទិន្នន័យ និងពិនិត្យប្រព័ន្ធផលិត និងផ្គត់ផ្គង់ទឹករបស់ស្ថានីយទាំង៥ (នៅស្រុកក្រូចឆ្មារ ស្រុកចំការលើ ស្រុកកំពង់ត្រឡាច ស្រុកម៉ាឡៃ និងស្រុកខ្សាច់កណ្តាល) ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែឧសភា និងថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៤។ ជាងនេះទៀត ក្រុមការងារក៏បានជួបប្រជុំតាមអនឡាញ និងជួបផ្ទាល់ជាមួយប្រតិបត្តិករជាម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំពង់ចំលង និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតសូទ្រនិគម ដើម្បីពិភាក្សាពីការប្តេជ្ញាចិត្តចូលរួមក្នុងគម្រោងនៅថ្ងៃទី៣១ ខែឧសភា និងថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៤។





*រូបភាពទី ២៦៖ ជំនួបជាមួយប្រតិបត្តិករនៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំពង់ចំលង និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំការលើ*

៦. ដើម្បីសិក្សាពីផែនការមេជូនប្រតិបត្តិករឱ្យបានរលូន ក្រុមការងារបានជួបប្រជុំជាមួយ **លោក យី សុកុល** ជានាយកប្រតិបត្តិ iSEA នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៤ ដើម្បីពិនិត្យ និងពិភាក្សាអំពីកិច្ចសន្យាអនុវត្តគម្រោង។ បន្ថែមពីនេះ អង្គការ Water.org និង សមាគម បានសម្របសម្រួលកិច្ចប្រជុំជាមួយក្រុមការងារ iSEA នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤ ដើម្បីពិភាក្សាអំពីវិធីសាស្ត្រ និងពេលវេលារបស់អនុវត្តការសិក្សាផែនការមេ។ ក្នុងនោះសមាគមបានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន iSEA ផងដែរ។

៧. ក្រុមការងារបានសម្របសម្រួលកិច្ចប្រជុំរវាងប្រតិបត្តិករទាំង ៦ស្ថានីយ និងក្រុមហ៊ុន iSEA នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ ដើម្បីពិភាក្សាលម្អិតអំពីវិធីសាស្ត្រ តម្រូវការព័ត៌មាន និងទិន្នន័យដែលត្រូវប្រមូលពីប្រតិបត្តិករ និងផែនការសកម្មភាពលម្អិតពីការសិក្សាផែនការមេ។



*រូបភាពទី ២៧៖ កិច្ចប្រជុំរវាងប្រតិបត្តិករទាំង ៦ស្ថានីយ និងក្រុមហ៊ុន iSEA*

### ៥.១.៥ ការសម្របសម្រួលកម្ចីរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងស្ថាប័នហិរញ្ញវត្ថុ

ក្រុមការងារគម្រោងបានសម្របសម្រួល និងតាមដានសមាជិកដែលទទួលបានប្រាក់កម្ចីពីស្ថាប័នហិរញ្ញវត្ថុ (FIs)។ ជាលទ្ធផល ប្រតិបត្តិករចំនួន ៣ស្ថានីយបានទទួលប្រាក់កម្ចីប្រមាណ ៩២២.៥០០ដុល្លារអាមេរិក ពីធនាគារ SME Bank ធនាគារ Prince Bank និងមូលនិធិ Stone Family Foundation ដើម្បីពង្រីកអាជីវកម្ម និង២ស្ថានីយទៀត កំពុងសិក្សាកម្ចីពីធនាគារ SME និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ AMK។

ក្រៅពីនេះសមាគមក៏បានណែនាំប្រតិបត្តិករដែលមានតម្រូវការកម្ចីឱ្យទំនាក់ទំនងទៅកាន់គ្រឹះស្ថានហិរញ្ញវត្ថុដែលជាសមាគម និងដៃគូរបស់អង្គការ Water.org ផងដែរ។

### ៥.១.៦ ការជំរុញកំណើនតំណអតិថិជនថ្មីជូនប្រតិបត្តិករ

ក្រុមការងារគម្រោងក៏បានជ្រើសរើសប្រតិបត្តិករចំនួន ៧ស្ថានីយ ក្នុងចំណោមសមាជិកគម្រោងចំនួន ៣៨ស្ថានីយ ដើម្បីចូលរួមបដិភាគក្នុងការផ្សព្វផ្សាយទីផ្សារបង្កើនតំណអតិថិជនថ្មី និងបានប្រកាសផ្សព្វផ្សាយនៅក្នុងគេហទំព័របងធំ ( Bongthom.com Website) និងប្រព័ន្ធសង្គមរបស់សមាគម ដើម្បីជ្រើសរើសក្រុមហ៊ុនប្រឹក្សាយោបល់ផ្នែកទីផ្សារ ក្នុងការអនុវត្តសកម្មភាពនេះ។ ប្រតិបត្តិករទាំង ៧ស្ថានីយ ដែលបានស្ម័គ្រចិត្តចូលរួមបដិភាគក្នុងគម្រោងរួមមាន៖

១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្វាយជ្រះ ខេត្តក្រចេះ
២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សូទ្រនិគម ខេត្តសៀមរាប
៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ចំការលើ ខេត្តកំពង់ចាម
៤. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត លី ហេង ខេត្តកំពង់ចាម
៥. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត មេសជ្រៃ-សូភាស ខេត្តកំពង់ចាម
៦. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឡេង ខៀវ ព្រែកអំបិល ខេត្តកណ្តាល
៧. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បាភ្នំ ខេត្តព្រៃវែង

### ៥.១.៧ កិច្ចប្រជុំរវាងអង្គការ Water.org និងសមាគម

ក្រុមការងារគម្រោងបានប្រជុំដូចតទៅ៖

១. នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤៖ ក្រុមការងារបានពិភាក្សាជ្រើសរើសក្រុមហ៊ុនប្រឹក្សាយោបល់ និងប្រតិបត្តិករចំនួន ៦ស្ថានីយ ដើម្បីរៀបចំផែនការមេ។
២. នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤៖ ក្រុមការងារពិភាក្សាអំពី ១) កិច្ចសន្យាជាមួយក្រុមហ៊ុន iSEA ២) ការងារគណនេយ្យរបស់ប្រតិបត្តិករជាមួយក្រុមហ៊ុន EW និងក្រុមហ៊ុន E-Water ៣)របាយការណ៍ពីការចុះផ្ទាល់ទៅកាន់ស្ថានីយទាំង ៣ស្ថានីយ ក្នុងចំណោម ៦ស្ថានីយ និង៤)ពិភាក្សាអំពីគម្រោងបន្ទាប់។



*រូបភាពទី ២៨៖ កិច្ចប្រជុំក្រុមការងារនៅការិយាល័យសមាគម*

## ៥.២ គម្រោង«សហគមន៍ដឹកនាំទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុប្រកបដោយបរិយាប័ន្ន»

នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៤ បុគ្គលិកសមាគមចំនួន ៣នាក់បានចូលរួមកិច្ចប្រជុំក្រុមការងារទឹកស្អាត និងអនាម័យថ្នាក់ស្រុក (DWG) នៅក្រុងព្រៃវែង ដែលគាំទ្រដោយអង្គការ EMW។ ក្នុងកិច្ចប្រជុំនេះ មានអ្នកចូលរួមសរុបចំនួន ២១នាក់ សមាសភាពរួមមាន៖ លោកអភិបាលរងក្រុង មន្ត្រីក្រុង បុគ្គលិក តំណាងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង ចៅសង្កាត់/ក្រុមប្រឹក្សា ទាំង០៤សង្កាត់ (សង្កាត់តាកោ សង្កាត់ជើងទឹក សង្កាត់កំពង់លាវ និងសង្កាត់បារាយណ៍) និងបុគ្គលិកសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។ កិច្ចប្រជុំនេះមានរបៀបវារៈសំខាន់ៗដូចខាងក្រោម៖

១. មតិស្វាគមន៍បើករបស់ **លោក អ៊ុំ វណ្ណធឿន** ជាអភិបាលរងក្រុងព្រៃវែង
២. បទបង្ហាញលទ្ធផល និងការរកឃើញបញ្ហានៃការប្រមូលទិន្នន័យប្រភព ដោយ **លោក ស៊ីន ស៊ីម**
៣. បទបង្ហាញលទ្ធផល និងការរកឃើញបញ្ហានៃការធ្វើបច្ចុប្បន្នភាពទិន្នន័យបង្គន់អនាម័យ គ្រួសារក្រីក្រមិនទាន់ទទួលបានសេវាទឹក អនាម័យ ការធ្វើផែនការឆ្លើយតប ការព្យាករណ៍ ODF+ និងលទ្ធផលសម្រេចបានត្រីមាសទី១ តាមបណ្តាស្រុក ក្រុង ដោយ **លោក ម៉ៅ ឈុនហ៊ាង**។



*រូបភាពទី ២៩៖ កិច្ចប្រជុំក្រុមការងារទឹកស្អាត និងអនាម័យថ្នាក់ស្រុក នៅក្រុងព្រៃវែង*

### ៥.៣ គម្រោង«ការពង្រឹងប្រព័ន្ធផែនការគ្រប់គ្រងធនធានទឹក សម្រាប់សេវាកម្មទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុ ប្រកបដោយបរិយាប័ន្ននៅក្នុងប្រទេសកម្ពុជា»

#### ៥.៣.១ វគ្គបង្វឹកផ្ទាល់

សមាគមបានផ្តល់វគ្គបង្វឹកផ្ទាល់ដល់ស្ថានីយទឹកស្អាតចំនួន២ លើប្រធានបទស្តីពី«**ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតកម្ពុជា**»។ ជាលទ្ធផល ស្ថានីយទាំង២ បានរៀបចំផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដោយជោគជ័យ ដោយមានការផ្តល់មតិយោបល់ និងឆ្លុះបញ្ចាំងពីអ្នកពាក់ព័ន្ធទៅលើមុខសញ្ញាគ្រោះថ្នាក់ទៅលើប្រព័ន្ធប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។ ជាងនេះទៅទៀត អ្នកពាក់ព័ន្ធទាំងអស់បានស្វែងយល់បន្ថែមពីផែនការរបស់ស្ថានីយនីមួយៗ ក្នុងការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទាំងមូល។

១. ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ រៀបចំនៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតពាម មានអ្នកចូលរួមសរុបចំនួន ០៦នាក់ (ស្រីចំនួន ០២នាក់) ដែលអញ្ជើញមកពីក្រុមប្រឹក្សាឃុំពាម តំណាងគ្រួសារក្រីក្រ តំណាងអង្គការជនមានពិការភាពស្រុកសាមគ្គីមានជ័យ និងស្ថានីយទឹកស្អាត។



*រូបភាពទី ៣០៖ កិច្ចប្រជុំក្រុមប្រឹក្សាឃុំពាម តំណាងគ្រួសារក្រីក្រ តំណាងអង្គការជនមានពិការភាព*

២. នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ រៀបចំនៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតមករា ស្វាយជុក មានអ្នកចូលរួមសរុបចំនួន០៧នាក់ (ស្រីចំនួន ០២នាក់) ដែលអញ្ជើញមកពីក្រុមប្រឹក្សាឃុំស្វាយជុក តំណាងគ្រួសារក្រីក្រ តំណាង អង្គការជនមានពិការភាពស្រុកសាមគ្គីមានជ័យ និងស្ថានីយទឹកស្អាត។



*រូបភាពទី ៣១៖ កិច្ចប្រជុំក្រុមប្រឹក្សាឃុំស្វាយជុក តំណាគ្រួសារក្រីក្រ តំណាងអង្គការជនមានពិការ*

### ៥.៣.២ កិច្ចប្រជុំផ្លុះបញ្ចាំងអំពី«ការសិក្សារៀបចំ និងការអនុវត្តន៍ ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ»

នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ បុគ្គលិកសមាគមសម្របសម្រួលរៀបចំកិច្ចប្រជុំស្តីពី«**ការសិក្សារៀបចំ និងការអនុវត្តន៍ ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ**» ដែលមានអ្នកចូលរួមសរុបចំនួន២៣នាក់ ស្រីចំនួន១០នាក់ ក្នុងនោះមាន លោកអភិបាលរងស្រុកសាមគ្គីមានជ័យ មន្ត្រីស្រុក ក្រុមប្រឹក្សាឃុំស្វាយ ក្រុមប្រឹក្សាឃុំតែ្បងខ្ពស់ ក្រុមប្រឹក្សាឃុំស្វាយជុក ក្រុមប្រឹក្សាឃុំពាម ក្រុមប្រឹក្សាឃុំឈានឡើង តំណាងសមាគមជនមានពិការភាពស្រុកសាមគ្គីមានជ័យ និងក្រុមការងារ CDRI។ កិច្ចប្រជុំនេះមានគោលបំណងក្នុងការសម្ភាសន៍អាផ្វាធរ ពីដំណើរការបង្កើតក្រុម និងការអនុវត្តន៍ ផែនការការសុវត្ថិភាពទឹក ធន់និងអាកាសធាតុ។



*រូបភាពទី ៣២៖ កិច្ចប្រជុំស្តីពី«ការសិក្សារៀបចំ និងការអនុវត្តន៍ ផែនការសុវត្ថិភាពទឹកធន់នឹងអាកាសធាតុ»*

## ៥.៤ គម្រោង«ការជ្រើសរើសប្រតិបត្តិករឯកជនផ្ទើមក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត» (JICA)

សមាគមបានសហការជាមួយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្រ្ត បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧវបន) និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តជាតិជប៉ុន (JICA) ក្នុងការអនុវត្តន៍គម្រោងមួយដែលមានឈ្មោះថា «ការជ្រើសរើស

ប្រតិបត្តិករឯកជនឆ្នើមក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត»។ គោលបំណងសំខាន់នៃគម្រោងនេះ គឺការចងក្រងនូវនីតិវិធីនៃការអនុវត្តល្អបំផុត ( ករណីសិក្សាជោគជ័យ- Success Story) តាមលក្ខណៈវិនិច្ឆ័យដែលគម្រោងបានកំណត់ ដើម្បីឱ្យប្រតិបត្តិករផ្សេងៗទៀត អាចយកទៅប្រើប្រាស់ ឬអនុវត្តតាម។

ក្រុមការងារបានរៀបចំសេចក្តីជូនដំណឹងប្រតិបត្តិករឱ្យដាក់ពាក្យចូលរួមក្នុងគម្រោង រៀបចំលក្ខណៈវិនិច្ឆ័យ និងវិធីសាស្ត្រក្នុងការជ្រើសរើសប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឆ្នើម។ ជាលទ្ធផល ស្ថានីយចំនួន ១៦ស្ថានីយបានដាក់ពាក្យចូលរួមក្នុងគម្រោង។ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនដែលជាសមាជិកសមាគមត្រូវបានបែងចែកជា៣ក្រុម រួមមាន៖

- **ក្រុមទី១៖** ប្រតិបត្តិករដែលមានសេវាកម្មគ្របដណ្តប់អតិថិជនចាប់ពី ០ ដល់ ៣.០០០គ្រួសារ/ខ្នងផ្ទះ។ ក្រុមទី១ នេះមានប្រតិបត្តិករដាក់ពាក្យចំនួន ១ស្ថានីយ។
- **ក្រុមទី២៖** ប្រតិបត្តិករដែលមានសេវាកម្មគ្របដណ្តប់អតិថិជនចាប់ពី ៣.០០១ ដល់ ៥.៥០០គ្រួសារ/ខ្នងផ្ទះ។ ក្រុមទី២ នេះមានប្រតិបត្តិករដាក់ពាក្យចំនួន ៥ស្ថានីយ។
- **ក្រុមទី៣៖** ប្រតិបត្តិករដែលមានសេវាកម្មគ្របដណ្តប់អតិថិជនចាប់ពី ៥.៥០១គ្រួសារ/ខ្នងផ្ទះឡើងទៅ។ ក្រុមទី៣ នេះមានប្រតិបត្តិករដាក់ពាក្យចំនួន ១០ស្ថានីយ។

នៅក្នុងត្រីមាសបន្ទាប់ ក្រុមការងារនឹងធ្វើការជ្រើសរើសប្រតិបត្តិករជាជំហានទី១ បន្ទាប់មកនឹងធ្វើការចុះសិក្សាលម្អិតដល់ស្ថានីយសម្រាប់ប្រតិបត្តិករដែលបានជ្រើសរើស។